**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧១ សសរ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការសំរាប់ចាត់ចែងការសាងសង់អាគារ សាកលវិទ្យាល័យខេត្តបាត់ដំបង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ និងស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមការចាំបាច់នៃការងារ

## សម្រេច

**ប្រការ ១.-** បង្កើតគណៈកម្មការសំរាប់ចាត់ចែងការសាងសង់អាគារសាកលវិទ្យាល័យរដ្ឋមួយនៅខេត្តបាត់ដំបង ដែលមាន សមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្តម **ប្រាជ្ញ ចន្ទ** | អភិបាលខេត្តបាត់ដំបង | ប្រធាន |
| ២- ឯកឧត្តម **អ៊ុយ ស៊ឹម** | ទីប្រឹក្សា និងជានាយកខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង** | អនុប្រធាន |
| ៣- ឯកឧត្តម **ចាន់ ណារ៉េត** | សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម | អនុប្រធាន |
| ៤- ឯកឧត្តម **មាស សារឹម** | ជាទីប្រឹក្សា និងនាយករងខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង** | សមាជិក |
| ៥- ឯកឧត្តម **ជា អឿន** | អគ្គនាយកនៃអគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញកិច្ច ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៦- លោក **ម៉ិត ច៊ុយ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានឧត្តមសិក្សា ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |

| | | |
|---|---|---|
| ៧- លោក **ឡាយ ម៉ូរិន** | ប្រធាននាយកដ្ឋានសំភារៈ និងទ្រព្យសម្បត្តិរដ្ឋ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៨- លោក **យូ ទីរះ** | អនុប្រធាននាយកដ្ឋានឧត្តមសិក្សា ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៩- លោក **ម៉ៅ ម៉ើ** | ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង | សមាជិក |
| ១០- លោក **ខួន រតនះ** | ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តបាត់ដំបង | សមាជិក |
| ១១- លោក **ឆៅ ប្រូច** | នាយកខុទ្ទកាល័យសាលាខេត្តបាត់ដំបង | សមាជិកអចិន្ត្រៃយ៍ |

**ប្រការ ២.**- គណៈកម្មការនេះមានភារកិច្ចដូចខាងក្រោម :

- សិក្សា និងលើកគំរោងនៃសំណង់អាគារសិក្សា និងចាត់ចែងការសាងសង់
- ចាត់ចែង គ្រប់គ្រងសំភារៈសំណង់ និងត្រួតពិនិត្យការសាងសង់
- ចាត់ចែង និងត្រួតពិនិត្យការបំពាក់គ្រឿងបង្គុំនៃសំណង់ និងគ្រឿងសង្ហារឹមនានា
- បំពេញការងារមួយចំនួនទៀតតាមការប្រគល់ភារកិច្ចពីក្រសួងអប់រំ យុវជន និងកីឡា និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ត្រូវរាយការណ៍ជាប្រចាំអំពីលទ្ធផលនៃការអនុវត្តការងារ ។

**ប្រការ ៣.**- សមាជិកទាំងអស់នៃគណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៤.**- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ព្រមទាំងអភិបាលខេត្ត ក្រុងដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងប្រការមួយ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៦

**ជ. នាយករដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រី**

**ស ខេង**

**កន្លែងទទួល :**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
- សាលាខេត្ត ក្រុងពាក់ព័ន្ធ
- ដូចចែងក្នុងប្រការ ៤
- ឯកសារ កាលប្បវត្តិ